# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម


២៩-១០-២០០៤ -ព្រះរាជក្រម នស/រកម/០០១ ច្បាប់ស្តីពីការរៀបចំព្រះបរមងារ និង ព្រះរាជសិទ្ធិថ្វាយអតីតព្រះមហាក្សត្រ និង ព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា ២៧៩២


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១៤-១២-២០០៤ -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល ២៧៩៦

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៨០៤

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨០៥

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨០៧

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨០៩

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨១១

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨១៣

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៦ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ២៨១៤

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨១៥

០៩-១២-២០០៤ -អនុក្រឹត្យលេខ ៦២៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨១៦

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦២៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៨១៧

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៨១៨

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៨១៩

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៨២០

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៨២១

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៨២២

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨២៤

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៦ អនក្រ.តត ស្តីពីការអនុវត្តវិន័យនាយនគរបាលជាតិ ២៨២៥

១៣-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៨២៧

១៤-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨២៨

១៤-១២-២០០៤ -អនុក្រឹត្យលេខ ៦៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨២៩

១៤-១២-២០០៤ -អនុក្រឹត្យលេខ ៦៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣០

១៤-១២-២០០៤ -អនុក្រឹត្យលេខ ៦៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣១

១៤-១២-២០០៤ -អនុក្រឹត្យលេខ ៦៤២ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ២៨៣២

១៥-១២-២០០៤ -អនុក្រឹត្យលេខ ៦៤៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨៣៤

១៥-១២-២០០៤ -អនុក្រឹត្យលេខ ៦៤៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ២៨៣៥

១៥-១២-២០០៤ -អនុក្រឹត្យលេខ ៦៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣៧

១៥-១២-២០០៤ -អនុក្រឹត្យលេខ ៦៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨៣៨


## ២. សេចក្តីសំរេច


០៩-១២-២០០៤ -សេចក្តីសំរេចលេខ ៧៥ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ២៨៤០

១៣-១២-២០០៤ -សេចក្តីសំរេចលេខ ៧៦ សសរ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យដំណើរការសាងសង់អាគាររដ្ឋបាលថ្មី នៃក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ២៨៤២

១៣-១២-២០០៤ -សេចក្តីសំរេចលេខ ៧៧ សសរ ស្តីពីការបង្កើតក្រុមការងារ សំរាប់ចុះទៅពិនិត្យដីមួយកន្លែងដែលមានទីតាំងនៅអតីតមណ្ឌលទទួលជនធ្វើមាតុភូមិនិវត្តន៍ កងវ៉ា ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ២៨៤៤

១៤-១២-២០០៤ -សេចក្តីសំរេចលេខ ៧៨ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ២៨៤៦

១៤-១២-២០០៤ -សេចក្តីសំរេចលេខ ៧៩ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង អនុវត្តសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ២៨៤៩

១៤-១២-២០០៤ -សេចក្តីសំរេចលេខ ៨០សសរ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំបញ្ជាការប្រយុទ្ធ ប្រឆាំង និង ទប់ស្កាត់អំពើភេរវកម្ម ២៨៥៣

## III-ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៣-១២-២០០៤ -ប្រកាសលេខ ៣៦៧ ប្រក.កសក ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូលិខិតអនុញ្ញាតក្នុងសកម្មភាពព្រៃឈើ ២៨៥៦

# ព្រះរាជក្រម

នស/រកម/១០០៤/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការរៀបចំព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិថ្វាយដល់អតីតព្រះមហាក្សត្រ និងព្រះរាជមហេសី នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ការរៀបចំព្រះបរមទារ និង ព្រះរាជបុព្វសិទ្ធិ ថ្វាយអតីតព្រះមហាក្សត្រ និង ព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំព្រះបរមងារ និង ព្រះរាជបុព្វសិទ្ធិថ្វាយអតីត **ព្រះមហាក្សត្រ និង ព្រះមហេសី** នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសំដែងនូវកតញ្ញូតា កតវេទិតាចំពោះព្រះមហាករុណាធិការៈដ៏ថ្លៃថ្លាខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់បានបំពេញជូនប្រជារាស្ត្រ ប្រជាជាតិ និងមាតុភូមិ ។

## ជំពូកទី ២
## ការរៀបចំព្រះបរមងារ និង ព្រះរាជបុព្វសិទ្ធិ

**មាត្រា ២.–**

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** អតីត **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបានថ្វាយព្រះបរមងារជា **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ។

**សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ព្រះមហេសីនៃព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ត្រូវបានថ្វាយព្រះបរមងារជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ។**

**មាត្រា ៣.–**

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ត្រូវបានរក្សាព្រះរាជបុព្វសិទ្ធិ អភ័យឯកសិទ្ធិពេញលេញនិង មិនអាចនរណារំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គគង់នៅគ្រងរាជសម្បត្តិ ។

**មាត្រា ៤.-**

រាល់ការចំណាយរបស់អតីតព្រះមហាក្សត្រ និង ព្រះមហេសីនៃអតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាបន្ទុកនៃថវិកាជាតិ ។

**មាត្រា ៥.-**

អតីតព្រះមហាក្សត្រ និង ព្រះមហេសីនៃអតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាមានព្រះរាជសិទ្ធិជ្រើសរើស និង តែងតាំងឥស្សរជននិងមន្ត្រីមួយចំនួនដើម្បីជាជំនួយការក្នុងការបំពេញព្រះរាជបេសកកម្ម ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.០៤១០.០០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

ហ៊ុន សែន

លេខ: ២០៧៤ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៣ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- តាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាភិបាលសាលាភូមិន្ទរដ្ឋបាល នាថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៤

# ស ៖ ស្រ ម ច

ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**

សាលាភូមិន្ទរដ្ឋបាល សរសេរអក្សរកាត់ ស.ភ.រ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ។

សាលាភូមិន្ទរដ្ឋបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

សាលាភូមិន្ទរដ្ឋបាល មានទីស្តីការគណៈរដ្ឋមន្ត្រីជាអាណាព្យាបាលផ្នែកបច្ចេកទេស និងមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២**

ទីស្នាក់ការរបស់សាលាភូមិន្ទរដ្ឋបាល តាំងនៅផ្លូវឧកញ៉ា ញ៉ឹក ជូឡុង ( ផ្លូវលេខ ៤៦៦ ) ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ៣**

សាលាភូមិន្ទរដ្ឋបាល មានបេសកកម្មជ្រើសរើស បណ្តុះបណ្តាល និងធ្វើវិក្រឹតការដល់មន្ត្រីរាជការដែលកំពុងបំពេញការងារនៅតាមក្រសួង-ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ។ សាលាភូមិន្ទរដ្ឋបាល មានភារកិច្ចរៀបចំវគ្គត្រៀមប្រឡងចូលសាលា ដោយផ្អែកលើកម្មវិធីសិក្សារបស់សាលា ។

**មាត្រា ៤**

ក្របខ័ណ្ឌដែលសាលាភូមិន្ទរដ្ឋបាលរៀបចំជ្រើសរើស បណ្តុះបណ្តាល ត្រូវកំណត់តាមបទប្បញ្ញត្តិនៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់មន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជា ឬតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ២
## ការគ្រប់គ្រងសាលាភូមិន្ទរដ្ឋបាល

**មាត្រា ៥**

សាលាភូមិន្ទរដ្ឋបាលគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និង នាយកសាលាមួយរូប ដែលមានអំណាចទូលំទូលាយ ដើម្បីគ្រប់គ្រងគ្រឹះស្ថាន ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់សាលា ។

**មាត្រា ៦**

សាលាភូមិន្ទរដ្ឋបាល ត្រូវស្ថិតនៅក្រោមការដឹកនាំនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្នុងឋានៈនេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធានក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទរដ្ឋបាល ដែលមានសមាជិកដទៃទៀតដូចមានរៀបរាប់ខាងក្រោម :

| | |
|---|---|
| - នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិកស្វ័យប្រវត្តិ |
| - តំណាងរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ១ រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប | សមាជិក |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប | សមាជិក |

ក្រៅពីនាយកសាលា សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា ៧**

ក្រុមប្រឹក្សាភិបាលប្រជុំសម្រេចលើបញ្ហាដែលបានស្នើឡើងដោយនាយកសាលា ។ នាយកសាលាត្រូវផ្តល់យោបល់ជាចាំបាច់ពីបញ្ហាដែលទាក់ទងការចាត់តាំង និងដំណើរការរបស់សាលា ។

ក្រុមប្រឹក្សាភិបាលមានបេសកកម្ម :

-អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សាលា កម្មវិធីសិក្សា របៀបបទរៀបចំការប្រឡង សមាសភាពគណៈមេប្រយោគ

-អនុម័តគម្រោងថវិការបស់សាលា

-អនុម័តលើរបាយការណ៍ប្រចាំឆ្នាំរបស់សាលា

-អនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលឧបសម្ព័ន្ធឯកទេស និងយល់ព្រមចំពោះគម្រោងនានា នៃ អនុសញ្ញា រវាងសាលាភូមិន្ទរដ្ឋបាល ជាមួយនឹងគ្រឹះស្ថានជាតិ សេវាជាតិ ឬអន្តរជាតិនានា

-ហើយជាទូទៅសម្រេចលើរាល់បញ្ហា ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលា ។

**មាត្រា ៨**

ក្រុមប្រឹក្សាភិបាលប្រជុំពីរដងក្នុងមួយឆ្នាំ តាមសម័យប្រជុំសាមញ្ញនៅសប្តាហ៍ទីមួយ នាខែ កុម្ភៈ និងខែ សីហា ។

ក្រុមប្រឹក្សាភិបាលប្រជុំវិសាមញ្ញ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកចំនួនពីរភាគបីឡើងទៅ ។

លិខិតអញ្ជើញប្រជុំ ត្រូវមានភ្ជាប់របៀបវារៈ ។

**មាត្រា ៩**

ក្រុមប្រឹក្សាភិបាលអាចប្រជុំបាន លុះណាតែមានសមាជិកចំនួនពាក់កណ្តាលវត្តមាន ។ សេចក្តីសម្រេចត្រូវធ្វើឡើង ដោយមតិភាគច្រើននៃសមាជិកដែលមានសិទ្ធិបោះឆ្នោតវត្តមាន ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព ។

សមាជិកក្រុមប្រឹក្សាភិបាល ចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលផ្ទាល់ខ្លួន ហើយមិនអាចបញ្ជូនតំណាងឱ្យមកជំនួស ឬឱ្យតំណាងបោះឆ្នោតជំនួសបានទេ ។

**មាត្រា ១០**

នាយកសាលាភូមិន្ទរដ្ឋបាល ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

**មាត្រា ១១**

នាយកសាលាមានបេសកកម្ម :

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ធានារ៉ាប់រងលើដំណើរការរបស់សាលា ដោយអនុវត្តតាមការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ធានារ៉ាប់រងការគោរពវិន័យផ្ទៃក្នុង ដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង
- រៀបចំថវិកា គណនីរដ្ឋបាល និងគណនីហិរញ្ញវត្ថុរបស់សាលា

- ជាអាណាប័កលើការចំណាយរបស់សាលាភូមិន្ទរដ្ឋបាល ស្របតាមការប៉ាន់ស្មានថវិកាប្រចាំឆ្នាំ
- រៀបចំការប្រឡងប្រជែង និងការប្រឡងនានា តាមគោលការណ៍ទូទៅនៃអនាមិកភាព និងការកែពីរលើក
- តែងតាំងគ្រូបណ្តុះបណ្តាលក្រៅគ្រឹះស្ថាន និងបុគ្គលិកសាលា
- រៀបចំកម្មសិក្សា
- ជ្រើសរើសបុគ្គលិកបង្ហាត់បង្រៀនសម្រាប់មុខវិជ្ជា រយៈពេលមានកំណត់ និងភ្នាក់ងារប្រតិបត្តិ
- បង្កើតអង្គការលេខ និងអង្គការចាត់តាំងនៃដំណើរការ និងការគ្រប់គ្រងសាលាភូមិន្ទរដ្ឋបាល
- ដាក់ជូនក្រុមប្រឹក្សាភិបាល នូវរបាយការណ៍ប្រចាំឆ្នាំ លើស្ថានភាពសីលធម៌ និងហិរញ្ញវត្ថុ និងគម្រោងអភិវឌ្ឍន៍របស់សាលា
- តំណាងសាលានៅចំពោះមុខសាលាជម្រះក្តី និងក្នុងការធ្វើលិខិតទាំងឡាយទាក់ទងនឹងជីវភាពស៊ីវិល
- ចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ទាក់ទងនឹងសេវារដ្ឋបាលសហគ្រាស អង្គការវិជ្ជាជីវៈកម្ពុជា បូបរទេស អង្គការ និងស្ថាប័នអន្តរជាតិនានា ដោយមានការផ្តល់យោបល់ឯកភាពពីក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៣
## ដំណើរការផ្នែកហិរញ្ញវត្ថុ

**មាត្រា ១២**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់សាលាភូមិន្ទរដ្ឋបាល ត្រូវស្ថិតនៅក្រោមគោលការណ៍នៃគណនេយ្យសាធារណៈ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យសាធារណៈ ដែលបានកំណត់ក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៣**

នាយកសាលាភូមិន្ទរដ្ឋបាល ជាអាណាប័កដើមខ្សែរបស់សាលា ។ ក្នុងន័យនេះ នាយកសាលាត្រូវមានភារកិច្ច :

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

ក្នុងការចំណាយរបស់សាលា អាណាប័កដើមខ្មែរអាចផ្តល់សិទ្ធិឱ្យទៅអាណាប័កផ្ទេរសិទ្ធិ ឬ អាណាប័កដើមខ្មែរអាចបង្កើតផ្នែកគ្រប់គ្រងវជ្ជទេយ្យចំណូល និងចំណាយ ដោយមានការយល់ព្រមពី គណនេយ្យករប្រតិស្រុត ដែលតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤**

គណនេយ្យករមួយរូប ទទួលបន្ទុកអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ទៅតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៣ ខាងលើ ។ គណនេយ្យករ ត្រូវចូលរួមការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងនាមអ្នកពិគ្រោះយោបល់ ។

**មាត្រា ១៥**

គណនេយ្យករ ត្រូវទទួលបន្ទុក :

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុក នូវលិខិតគតិយុត្តិការ និងកាន់បញ្ជីគណនេយ្យ

គណនេយ្យករ អាចផ្ទេរសិទ្ធិខ្លះឱ្យទៅមន្ត្រីក្នុងការិយាល័យបាន ។

**មាត្រា ១៦**

ប្រភពធនធានរបស់សាលារួមមាន :

- ធនធានដំបូងដែលរដ្ឋផ្តល់ឱ្យ នៅពេលចាប់ផ្តើមបង្កើតសាលា
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលបានកំណត់ក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទាន ដែលសាលាបានទទួល
- ផលនៃការខ្ចី
- ផលនៃការងារ ការកាលិក និងសេវាដែលសាលាបានផ្តល់ឱ្យ
- ចំណូល ដែលបានមកពីទ្រព្យសម្បត្តិ ដែលអនុញ្ញាតដោយរាជរដ្ឋាភិបាល ។

**មាត្រា ១៧**

ចំណូល និងចំណាយជាប្រចាំ និងជាមូលធនរបស់សាលាភូមិន្ទរដ្ឋបាល ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់សាលា ។

ក្រុមប្រឹក្សាភិបាល ត្រូវចែងអំពីបែបបទនៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៨**

ការងារគណនេយ្យរបស់សាលាភូមិន្ទរដ្ឋបាលរួមមាន :

- ឯកសារផ្នែកគណនេយ្យទូទៅ ត្រូវធ្វើជាពីរច្បាប់ ។ ឯកសារនេះកត់ត្រានូវប្រតិបត្តិការទាំងឡាយផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការផ្នែករតនាគារ និងប្រតិបត្តិការដែលធ្វើជាមួយតតីយជន ។

- បញ្ជីសារពើភ័ណ្ឌអចលនទ្រព្យ រូបធាតុ និងវត្ថុមានតម្លៃ ។

ការងារគណនេយ្យរបស់សាលាត្រូវ :

- ស្របតាមការកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- គោរពតាមប្លង់គណនេយ្យ ដែលយល់ព្រមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៩**

គណនេយ្យករ និងអាណាប័កដើមខ្សែ ត្រូវរៀបចំគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការគ្រប់គ្រង រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច យ៉ាងយូរបំផុត ៣ ខែ បន្ទាប់ពីការបិទការិយបរិច្ឆេទគណនេយ្យ ។

មូលនិធិរបស់សាលាភូមិន្ទរដ្ឋបាល គឺជាមូលនិធិសាធារណៈ ដែលចាំបាច់ត្រូវតែតម្កល់ក្នុងគណនីមួយ ដែលត្រូវបើកនៅរតនាគារជាតិ លើកលែងតែមានបទប្បញ្ញត្តិ ដែលយល់ព្រមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## របបសារពើពន្ធនៃសាលាភូមិន្ទរដ្ឋបាល

**មាត្រា ២០**

លើកលែងតែមានបទប្បញ្ញត្តិរបស់ច្បាប់ សាលាភូមិន្ទរដ្ឋបាល ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២១**

អនុក្រឹត្យលេខ ៨០ អនក្រ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី*

*" ដើម្បីសុំហត្ថលេខា "*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៦២០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ទោ **ជុំ ពោធិរិទ្ធ** អត្តលេខ ០៧៨៥

២- លោកវរៈសេនីយ៍ទោ **កែប សុវណ្ណដារ៉ា** អត្តលេខ ០១៩៧៧

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧២១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងអគ្គលេខាធិការរងនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឱម សុភាព** | ទទួលការងារហេដ្ឋារចនាសម្ព័ន្ធ | |
| ២-ឯកឧត្តម | **ចូន តាំងលាង** | ទទួលការងាររៀបចំខ្លឹមសារ និងកម្មវិធី | |
| ៣- លោក | **ជាវុឌ្ឍិ សុខេរីន** | ទទួលការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ | មានឋានៈស្មើ អគ្គនាយករង |
| ៤- លោក | **សួង ណាយ** | ទទួលការងារអភិវឌ្ឍន៍ធនធានមនុស្ស | មានឋានៈស្មើ អគ្គនាយករង |
| ៥- លោក | **ជុន ម៉ាត** | ទទួលការងារអភិវឌ្ឍន៍សហគ្រាស | មានឋានៈស្មើ អគ្គនាយករង |
| ៦- លោក | **ឆាយ ង៉ៃ** | ទទួលការងារគ្រប់គ្រងរដ្ឋបាលទូទៅ | មានឋានៈស្មើ អគ្គនាយករង |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ក.ស.ស.ស)
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សំរេច

**មាត្រា ១.-**

ត្រូវបានតែងតាំងសមាសភាពប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន ក.ស.ស.ស រួមមានៈ

១- លោក **ញឹម មុខ៉ាន** ប្រធានផ្នែក សង្គមកិច្ច ការងារ វប្បធម៌ និង ពត៌មាន

២- លោក **ហ៊ី គីមហៀង** ប្រធានផ្នែក រដ្ឋបាល ផ្គត់ផ្គង់ និងហិរញ្ញកិច្ច

៣- លោក **ឡោ ម៉ូលីណា** ប្រធានផ្នែក ដឹកជញ្ជូន ប្រៃសណីយ៍ ទូរគមនាគមន៍ និងសំណង់

៤- លោក **ទៅ៉ សុខ៊ាង** ប្រធានផ្នែក កសិកម្ម អភិវឌ្ឍន៍ជនបទ និងសេវាកម្ម

៥- លោក **ឌេស រុក្ខាផល** ប្រធានផ្នែក ឧស្សាហកម្ម អគ្គិសនី និង ទេសចរណ៍

៦- លោក **ប៊ិច សុខា** ប្រធានផ្នែក សេដ្ឋកិច្ច ហិរញ្ញវត្ថុ និង ធនាគារ

៧- លោក **ច៊ាន់ តិរុណ** ប្រធានផ្នែក សារព័ត៌មានឯកសារ និង ពត៌មានវិទ្យា

ប្រធានផ្នែកនីមួយៗ ត្រូវបានតែងតាំងឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

ចំលងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងតំបន់ប្រតិបត្តិការសឹករងកោះកុង ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយថ្នាក់ស្ថាបនាជាតិ :**

- វរសេនីយ៍ឯក **យន្ត មីន** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងកោះកុង ទឹកប្រាក់ ៥.៣៥០ ដុល្លារ

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-វរសេនីយ៍ទោ **សុខសុចត្ថិ នុម** មេបញ្ជាការរង និង ជានាយសេនាធិការតំបន់ប្រតិបត្តិការសឹករងកោះកុង ទឹកប្រាក់ ១.១០០ ដុល្លារ

២-វរសេនីយ៍ **សំឃីត ទៀន** ស្នងការរង នគរបាល ខេត្តកោះកុង ទឹកប្រាក់ ១.១០០ ដុល្លារ

៣-អនុសេនីយ៍ឯក **ឃឹម សម្បត្តិ** មេបញ្ជាការផ្នែកសឹករង ស្រុកមណ្ឌលសីមា ទឹកប្រាក់ ១.១០០ ដុល្លារ

៤-អនុសេនីយ៍ឯក **អាន វស្សវិទ** មេបញ្ជាការរង វរសេនាតូចលេខ ២៦៩ ប៉ូលីសព្រំដែនទឹក ទឹកប្រាក់ ១.១០០ ដុល្លារ

៥ អនុសេនីយ៍ឯក **ឈៀង គីមឃាន់** មេបញ្ជាការកងរាជអាវុធហត្ថ ស្រុកបព្ទាយស្រីម៉ា ទឹកប្រាក់ ១.១០០ ដុល្លារ

៦ អនុសេនីយ៍ **សៀង ឡេត** នគរបាល ខេត្តកោះកុង ទឹកប្រាក់ ១.៥០០ ដុល្លារ

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ ៨ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច /
- ឯកសារ-កាលប្បវត្តិ

B 46 47

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៦៧៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពី ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សម្រេច

**មាត្រា ១ :** តែងតាំងសមាសភាពប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដោយពុំមានការផ្លាស់ប្តូរឋានៈបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- លោក **ឆឹង សុខែ** | ជាប្រធានផ្នែកច្រកចេញចូលតែមួយ និងការផ្តល់សេវាសាធារណៈ |
| ២- លោក **ឈឹម ផារ៉ិន** | ជាប្រធានផ្នែកវិភាគការងារប្រតិបត្តិ របស់ក្រសួង ស្ថាប័ន |
| ៣- លោក **អ៊ុក សំបូរ** | ជាប្រធានផ្នែកគ្រប់គ្រងក្របខ័ណ្ឌ និងអធិការកិច្ច |
| ៤- លោក **យិន ឈន** | ជាប្រធានផ្នែករដ្ឋបាល និងបុគ្គលិក |
| ៥- លោក **ច្រាក់ ទីត្រា** | ជាប្រធានផ្នែកផ្គត់ផ្គង់ |

**មាត្រា ២ :** តែងតាំងសមាសភាពប្រធានផ្នែកនានា នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដូចមាន រាយនាមខាងក្រោម :

១- លោក **ហុក ម៉េងសែ** ប្រធានផ្នែកវិសហមជ្ឈការ និងវិមជ្ឈការបច្ចេកទេស
មានឋានៈស្មើ អគ្គនាយករង

២- លោក **គង់ សុភី** ប្រធានផ្នែកកម្មវិធីកន្សោមអាទិភាព មានឋានៈស្មើ អគ្គនាយករង

៣- លោក **ស្វាយ សុវណ្ណរិទ្ធ** ប្រធានផ្នែកគោលនយោបាយលាភការ និង ការពង្រាយមន្ត្រីរាជការ
មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៤- លោក **នាយ នត្រាវុធ** ប្រធានផ្នែកតារាងទូទាត់បៀវត្ស និង កិច្ចការនីតិកម្ម
មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៥- លោក **ខា មានិត** ជាប្រធានផ្នែកទំនាក់ទំនង និងបច្ចេកវិទ្យា ពត៌មានវិទ្យា
មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៦- លោក **ខឹន ចរិន្ត** ជាប្រធានផ្នែកអភិវឌ្ឍន៍សមត្ថភាព មានឋានៈស្មើ ប្រធាននាយកដ្ឋាន

៧- កញ្ញា **នាង លីណា** ជាប្រធានផ្នែកអភិបាលកិច្ច មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នរដ្ឋ
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ម៉ិត ចាន់ធូ** ប្រធានឡត៍នេសាទ លេខ១៨ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយជីកស្តារប្រឡាយព្រែក ចំនួន ០៤ ខ្សែ នៅស្រុកល្វាឯម ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ ចំនួន ៤៥២.២៦៦.០០០ រៀល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.5.3

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា១ :**

ត្រូវបានបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ២០០កន្លែង (ពីររយ) ដល់ក្រសួងមហាផ្ទៃ សំរាប់បំពេញតម្រូវការចាំបាច់នៃការងារការពារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម ។

**មាត្រា២ :**

ក្របខ័ណ្ឌបន្ថែមថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិចាប់ពីខែ មករា ឆ្នាំ២០០៥ តទៅ ។

**មាត្រា៣ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៤
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣*
- *កាលប្បវត្តិ-ឯកសារ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំងមន្ត្រីរាជការស៊ីវិលនៃក្រសួងទេចរណ៍ ដូចមានរាយនាមខាងក្រោម:

១-លោក **ហោ សារុន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

២-លោក **ច័ន្ទ តារា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

៣-លោក **សៀង គឹមហាន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទេសចរណ៍ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សម្រេច

**មាត្រា ១** : តែងតាំងមន្ត្រីរាជការនៃក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម :

១- លោក **ហាស់ សំអាត** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលសោតទស្សន៍ នៃក្រសួងពត៌មាន

២- លោក **ជុំស សុវណ្ណ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលសោតទស្សន៍ នៃក្រសួងពត៌មាន

៣- លោក **ជា សាខុន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានកម្ពុជា AKP នៃក្រសួងពត៌មាន

៤- លោក **សរ មុយលី** ជាប្រធាននាយកដ្ឋានពត៌មានវិទ្យុផ្សាយទៅបរទេស នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មាន

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤២៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៙

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកពលបាលឯក **ចារ៉ើន ស៊ូខាង** ( ***SM2 JAROEN SUKANG*** ) ជំនួយការអនុព័ន្ធយោធា នៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការលើក ស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការ រវាងកងទ័ពប្រទេសទាំងពីរ កម្ពុជា-ថៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✗4

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច /
-ឯកសារ-កាលប្បវត្តិ

B.66

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: [illegible]

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៛

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានចំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ឯក **រ៉ូហ្សឺ ចន ម៉ាក់អែលវ៉ែន** ( ***Colonel Roger John McElwain*** ) សេនាធិការ *New Zealand* ប្រចាំព្រះរាជាណា ចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការ រវាងកងទ័ព ប្រទេសទាំងពីរ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✕+

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៤ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ⁄
-ឯកសារ-កាលប្បវត្តិ

B 66

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧១ ... អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ឧបឧិន្ទ** ជូនលោក **អង់តូនី ជូដ** នាយករងស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ( ***Mr. Anthony J. Jude, Deputy Head of Asian Development Bank ,Cambodia Resident Mission*** ) ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការជួយអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា រយៈពេល ០៥ ឆ្នាំ កន្លងមក ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ ✗✗

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៣២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនឯកឧត្តម **សាំង សារ៉ែន** ទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាជាតិ ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការជួយកសាង និង អភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា សង្គមកិច្ច និង ជីវភាពប្រជាពលរដ្ឋ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៧៣ អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកបណ្ឌិត ***Daniel Arghiros*, *Head Office of Department for International Development* , *DFID*** ដែលមានស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការ ជួយដល់កម្មវិធីសិលា នៅព្រះរាជាណាចក្រកម្ពុជា រយៈពេល ០៤ ឆ្នាំ កន្លងមក ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ នៃ កម្មវិធីសិលា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

B..13

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាទូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីនៃរាជាយស្វ័យយានកម្ពុជា ចំនួន ១១ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើវិស័យដឹកជញ្ជូនផ្លូវដែក ដូចមានរាយនាមខាងក្រោម :

១-លោក **ហ៊ុយ រិទ្ធ** នាយក ក្បាលម៉ាស៊ីន និង ទូរថភ្លើង

២-លោក **លី បូរិន** នាយក ផ្លូវ ស្ពាន អាគារ

៣-លោក **ឌុ សារ៉ា** នាយក រដ្ឋបាល

៤-លោក **វៃ រឿន** នាយក អាជីវកម្មដឹកជញ្ជូន

៥-លោក **សុខ ឈរាធី** នាយករង អាជីវកម្មដឹកជញ្ជូន

៦-លោក **ញ៉ឹក ធីរត្នរ័ន្ត** នាយករង រដ្ឋបាល

៧-លោក **ស៊ូ ផល្លី** ប្រធានការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុ

៨-លោក **អ៊ុំ សុមន្តា** នាយករង ក្បាលម៉ាស៊ីន និង ទូរថភ្លើង

៩-លោក **ឈុន យុខ** នាយករង រដ្ឋបាល

១០-លោក **ចំន្ទ សំឡេង** នាយករង ផ្លូវ ស្ពាន អាគារ

១១-លោក **ខៀវ ប៊ុនតឹក** ប្រធានតំបន់ផ្លូវដែកបាត់ដំបង

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៣៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា១.-**

តែងតាំងមន្ត្រីរាជការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោម :

១-លោក **គឹម ចន្ទ្រា** ជាអគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុ
២-លោក **សេខ សុធា** ជាអគ្គាធិការរង
៣-លោក **សុខ សុផល** ជាអគ្គាធិការរង
៤-លោក **ស៊ឹម ញាណ** ជាអគ្គាធិការរង
៥-លោកស្រី **ជា ឧត្តរារី** ជាអធិការ

**មាត្រា២.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ក្នុងមាត្រា១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៤
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៧៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តវិន័យនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម /០៧០៤ / ០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ .-**

ត្រូវបានអនុវត្តវិន័យចំពោះវរសេនីយ៍ឯក សូ សាន្ត អត្តលេខ ០២០៤៨ ភេទប្រុស ឋានៈអនុប្រធានសេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដោយរូបភាពដកហូតមុខតំណែង ឋានន្តរសក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ មូលហេតុ : បោះបង់ចោលការងារ ។

មាត្រា២ . ـ

ប្រាក់បៀវត្សរ៍ របបឧបត្ថម្ភផ្សេងៗ និងក្របខណ្ឌត្រូវបានលុបឈ្មោះចេញពីនគរបាលជាតិចាប់ពីខែ..........ឆ្នាំ២០០៤ នេះតទៅ ។

មាត្រា៣ . ـ

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ . ـ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៤*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនមន្ត្រីជំនួយការផ្ទាល់ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-លោក **សុត ស្មើ**

២-លោក **ពៅ ថាវី**

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

B 37

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៣៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

~~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងលោក **ស៊ឹម សារន** ជាប្រធាននាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ
~~~~~~~~~~

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន *Japan Amusement Business Group ( NSA , JAMMA , AOU )* ដែលបានជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៤បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ អស់ទឹកប្រាក់ចំនួន ៣១.៦៥០ ដុល្លារ ជូនសាលាបឋមសិក្សាទីពមានជ័យ ស្រុក គងពិសី ខេត្តកំពង់ស្ពឺ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ✗✓

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

B.74

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៧៤០...អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានជួយកសាងអគារសិក្សា ០១ខ្នង និងទីចាត់ការ ០១ខ្នង ដោយមានបំពាក់សម្ភារឹមគ្រប់គ្រាន់ ជូនសាលាបឋមសិក្សាទួលសុវង្ស ក្នុងឃុំវាយពុង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចំណាយអស់ទឹកប្រាក់ ចំនួន ២៨.៤៨៣ដុល្លារ ដូចមានរាយនាមខាងក្រោម :-

១-ព្រះតេជគុណ **អ៊ុន ឡឿន** ចៅអធិការវត្តធ្លាចាស់

២-លោកស្រី **លឹម អាំងឌូ** សប្បុរសជន នៅប្រទេសអូស្ត្រាលី

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៩ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.75

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ចំនួន ០២គ្រឿង ជូនក្រុមហ៊ុន និងសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង និងអណ្តូងទឹកស្អាត០១ រួមទាំងសម្ភារៈសិក្សាគ្រប់គ្រាន់ ជូនសាលាបឋមសិក្សា កំពង់ត្រាច ក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

-ក្រុមហ៊ុន **MY.TECH** ថវិកា ចំនួន ១៧.៥១១ USD

**ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោកស្រី **KAWACHI HISAE** ថវិកា ចំនួន ៤.៩៣៥.៨០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.70

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៤៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម:

១- ផ្ទេរភារកិច្ចលោក **ហ៊ុខ ថវ** បច្ចុប្បន្នជាប្រធាននាយកដ្ឋានពន្ធដារ ទៅបំរើការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

២- តែងតាំងលោក **ស៊ឹម សឿន** បច្ចុប្បន្នជាអនុប្រធាននៃនាយកដ្ឋានពន្ធដារ ជាប្រធាននាយកដ្ឋានពន្ធដារ ។

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល**:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៦៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាច្បាប់ និងប្រព័ន្ធយុត្តិធម៌

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ម៉ែន មុនីឈា** ជានាយករងអង្គភាពគ្រប់គ្រងគំរោងកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៤ អនក្រ.ទត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនសព ÷

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ទោ | ឡៅ | សាវី | អត្តលេខ ០០១២៣៤ | នាយទាហានការពារផ្ទាល់ អង្គរក្ស សម្តេចប្រធានព្រឹទ្ធសភា |
| ២-វរសេនីយ៍ទោ | សេង | ឡឿម | អត្តលេខ ០០០៧៤៨ | នាយ ការិយាល័យផ្តល់ពត៌មាន សេនាធិការដ្ឋាន កងអន្តរាគមន៍ |
| ៣-វរសេនីយ៍ទោ | ហាឡូ | សាមី | អត្តលេខ ០០២១៦២ | នាយរង ការិយាល័យចលនូបត្ថម្ភ សេនាធិការដ្ឋាន កងអន្តរាគមន៍ |
| ៤-វរសេនីយ៍ទោ | សរ | សំអ៊ាន | អត្តលេខ ០០៣៤៣៦ | នាយរង ការិយាល័យអធិការកិច្ច បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន |

៥-វរសេនីយ៍ទោ ញ៉ិប ថួក អត្តលេខ ០០៩៤០៥ នាយសេនាធិការរង កងពលតូចទ័ពពិសេសឆ័ត្រយោង៩១១

៦ វរសេនីយ៍ទោ ស៊ិន ម៉ិន អត្តលេខ ០០៣០០៦ នាយ ការិយាល័យទី៣ យោធភូមិភាគទី ៥

៧-វរសេនីយ៍ទោ ឥចំ ឧត្តម អត្តលេខ ០០១០២៦ នាយរង ការិយាល័យទី៣ យោធភូមិភាគទី ៥

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវ អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៤៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានធ្វើអំណោយ ជាម៉ាស៊ីន កុំព្យូទ័រ ចំនួន ២៨៣គ្រឿង ជូនដល់បញ្ជាការដ្ឋានកងទ័ពជើងគោក ដូចមានរាយនាមខាងក្រោម :-

១-លោក **តាំង ជិនហួរ** *( Mr.Tang Chin Hua )* នាយកក្រុមហ៊ុន យុងវ៉ា ទឹកប្រាក់ ១០.០៥០ ដុល្លារ

២-លោក **លឹម ប៊ុនគង** *( Mr.Lim Boon Kwang )* នាយករងក្រុមហ៊ុន យុងវ៉ា ទឹកប្រាក់ ១០.០៥០ ដុល្លារ

៣-លោក **ចាក់គី ហ្គោ វេ ជីន** *( Mr.Jackie Goh Wei Chin )* សមាគមយុវជនសិង្ហបុរី ទឹកប្រាក់ ៧៩.៩០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.54

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៤៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រភេទ និងជូនសប្បុរសជនចំនួន ១០ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួម[illegible] សាលាពុទ្ធិកសិក្សា និង សមិទ្ធផលជាច្រើនទៀត នៅក្នុងវត្ត[illegible] ឃុំជង្រុក ស្រុក[illegible] ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាម និង នាមខាងក្រោម ៖

**ក. មេដាយមាសស្ថាបនាជាតិ ៖**

១- ព្រះតេជគុណ **សាន មុនី** បច្ច័យចំនួន ១៣.២០០ដុល្លារ

២- ឧត្តមសេនីយ៍ទោ **ទៀវ សុខ្ខ** និង លោកជំទាវ [illegible] ព្រមទាំងបុត្រ ទឹកប្រាក់ចំនួន ១៣.១៩៥ដុល្លារ

៣- លោក **ឈឹម ជាងគេខខាង** និងលោកស្រី [illegible] ទឹកប្រាក់ចំនួន ១៣.៧៧៥ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិ ៖**

១- កញ្ញា ឃឹន សេនា [illegible] មកពីសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.៥០០ដុល្លារ

២- លោក **ឡឹម ទូណា** និងអ្នកស្រី **ឈឹម ឈុនឌី** ព្រមទាំងបុត្រ មកពីសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ

៣- លោក **ឆាំង សេខឡើ** និងអ្នកស្រី **ចិន្តា ចិន** ព្រមទាំងបុត្រ ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ

៤- ឧបាសក **ឈឹម សេន** និងឧបាសិកា **មាស យី** ព្រមទាំងបុត្រ ទឹកប្រាក់ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសុវត្ថិស្ពានធនាជាតិ :**

១ កញ្ញា **ហុក ធន់ថា** និង លោកឪពុក អ្នកម្តាយ ទឹកប្រាក់ចំនួន ២.៩០០ ដុល្លារ

២-ឧបាសិកា **ចាន់ ឃៀងហ៊ុន** និងបុត្រ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.០០០ ដុល្លារ

៣-លោក **អ៊ុំ សែឃួ** និង អ្នកម្តាយ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១.៨៨៧.៥ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើត ក្រុមការងារអន្តរក្រសួង
## រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១.-**

បង្កើតក្រុមការងារអន្តរក្រសួងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- | ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| ៣- | ឯកឧត្តមរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| ៤- | ឯកឧត្តមរដ្ឋលេខាធិការក្រសួងការពារជាតិ ១ រូប | សមាជិក |
| ៥- | ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | សមាជិក |

៦- ឯកឧត្តមរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ រូប សមាជិក

៧- ឯកឧត្តមអគ្គទេសាភិបាលរងធនាគារជាតិកម្ពុជា ១ រូប សមាជិក

៨- ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ១ រូប សមាជិក

**ប្រការ២.-**

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម :

- សិក្សាស្រាវជ្រាវអនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម
- តាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម អោយស្របទៅនឹងអនុសញ្ញាអន្តរជាតិទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ដែលកម្ពុជាបានចុះហត្ថលេខារួចហើយ
- ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចអោយបានល្អប្រសើរ និងជំរុញការងារអោយមានដំណើរការទៅមុខបានឆាប់រហ័ស ។

**ប្រការ៣.-**

ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ដើម្បីដំណើរការការងារ ។

សមាជិកក្រុមការងារអន្តរក្រសួង ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ច ដែលបានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៤.-**

ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិគ្រប់គ្រាន់ដើម្បីបង្កើតក្រុមការងារបច្ចេកទេសមួយ ជាជំនួយការ ដែលមានសមាជិកជាមន្ត្រីជំនាញជ្រើសរើសចេញមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធខាងលើ ព្រមទាំងអ្នកឯកទេសបរទេស និងអន្តរជាតិមួយចំនួនទៀត ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧៤៦ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការត្រួតពិនិត្យដំណើរការសាងសង់អាគាររដ្ឋបាលថ្មី នៃក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញសេចក្តីជូនដំណឹងលេខ ១៤២១ សជណ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយដែលមានសមាសភាពដូចខាងក្រោម :

១-លោកជំទាវ **ម៉ែន សំអន** ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ជាប្រធាន

២-ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ ជាអនុប្រធាន

៣-ឯកឧត្តម **អ៊ុត អ៊ីប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៤- ឯកឧត្តម **នូត ណារ៉ាង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក

៥-ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**ប្រការ២:** គណៈកម្មការនេះ មានភារកិច្ចជំរុញ និងត្រួតពិនិត្យដំណើរការសាងសង់អាគារថ្មីនៃ ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលសាងសង់ដោយក្រុមហ៊ុន ញូវ ហួព ខូអិលធីឌី លើផ្ទៃដី ទំហំ ៥.៣៦៦$ម^2$ លើដីសួនខាងលិចបុកប៊ូឌីញ ស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ អភិបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានក្នុងប្រការមួយត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ [illegible] សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារ សំរាប់ចុះទៅពិនិត្យដីមួយកន្លែង ដែលមានទីតាំងនៅអតីតមណ្ឌលទទួលជនធ្វើមាតុភូមិនិវត្តន៍កងវ៉ា ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១** : បង្កើតក្រុមការងារមួយសំរាប់ចុះទៅពិនិត្យដីមួយកន្លែងដែលមានទីតាំងនៅអតីតមណ្ឌលទទួលជនធ្វើមាតុភូមិនិវត្តន៍កងវ៉ា ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **យូ អយ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ប្រធាន |
| ២-ឯកឧត្តម | **ឃួន វ៉ានីន** | អគ្គនាយកកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៣-លោក | **អ៊ិត រ៉ាឌី** | អគ្គាធិការរង ក្រសួងយុត្តិធម៌ | សមាជិក |
| ៤-លោក | **ប៊ុក សារុយ** | អភិបាលរងទី៣ ខេត្តបន្ទាយមានជ័យ | សមាជិក |
| ៥-លោកស្រីឧត្តមសេនីយ៍ត្រី | **អ៊ិន សុគន្ធា** | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-លោក | **ហ៊ុយ ផាប់** | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

**ប្រការ២** : ក្រុមការងារនេះមានភារកិច្ច សហការជាមួយអាជ្ញាធរដែនដី គ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះទៅពិនិត្យស្រាវជ្រាវដល់ទីកន្លែងផ្ទាល់ និងប្រមូលឯកសារសំខាន់ៗ និងពត៌មានជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

**ប្រការ៣** : សមាជិកទាំងអស់របស់ក្រុមការងារ ត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមាន ឈ្មោះក្នុងប្រការ ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនិងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៨ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការចំរុះអន្តរក្រសួងដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវករណីពាក្យបណ្តឹងរបស់សមាគម **AFESIP** ចំពោះសកម្មភាពរបស់សណ្ឋាគារ ឆាយ ហួរ II និង អំពីសកម្មភាពរបស់

សមាគម **AFESIP** ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា | ប្រធាន |
| ២- តំណាងក្រសួងកិច្ចការនារី | អនុប្រធាន |
| ៣- តំណាងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៤- តំណាងក្រសួងទំនាក់ទំនងសភា និង អធិការកិច្ច | សមាជិក |
| ៥- តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៦- តំណាងក្រសួងមហាផ្ទៃ | សមាជិក |

ប្រការ២ : គណៈកម្មការចំរុះអន្តរក្រសួងនេះមានភារកិច្ច ៖

- ធ្វើការស៊ើបអង្កេតស្រាវជ្រាវអំពីសកម្មភាពរបស់សណ្ឋាគារ **ឆាយ ហួរ II** ស្ថិតនៅផ្លូវលេខ ២៧៥ សង្កាត់ផ្សារដេប៉ូ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ និង របស់សមាគមសង្គ្រោះ និងស្តារនិតិសម្បទាយុវនារី ( **AFESIP** ) ស្ថិតនៅផ្លូវលេខ ៣១៥ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។
- អញ្ជើញនារីទាំង ៨៣នាក់ ដែលសមត្ថកិច្ចនគរបាលបានចាប់ចេញពីសណ្ឋាគារ **ឆាយ ហួរ II** កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ មកសាកសួរធ្វើសំភាសន៍នៅចំពោះមុខតំណាងស្ថានទូត និង តំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលជាអ្នកសង្កេតការណ៍ និងជាសាក្សី ។
- តាមដានពាក្យបណ្តឹងបុគ្គលិកកម្មករ បំរើការងារនៅសណ្ឋាគារ **ឆាយ ហួរ II** ដែលស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានបញ្ជូនទៅតុលាការក្រុងភ្នំពេញ ។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការស៊ើបអង្កេតស្រាវជ្រាវជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។
- ធ្វើការងារផ្សេងៗទៀត ដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

ប្រការ៣ : សមាជិកគណៈកម្មការចំរុះអន្តរក្រសួងត្រូវចូលរួមប្រជុំ និងបំពេញភារកិច្ចតាមការអញ្ជើញ និងការចាត់តាំងរបស់ប្រធាន ។

ប្រការ៤ : គណៈកម្មការចំរុះអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ក្នុងកិច្ចការជាផ្លូវការរបស់ខ្លួន ។

ប្រការ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បណ្តាស្ថាប័នក្រសួងដែលពាក់ព័ន្ធដូចក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៤**

**ជ. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

ស ខេង

**ចម្លងជូន :**

- ទីស្តីការរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

  " ដើម្បីជូន និងថ្វាយជ្រាប "
- ដូចប្រការ១ និងប្រការ៥ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងអនុវត្តសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យគ្មានលេខ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ពាក់ព័ន្ធនឹងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីវិសោធនកម្មព្រះរាជក្រឹត្យគ្មានលេខ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះអន្តរក្រសួងរួមជាមួយមន្ត្រីខេត្តបាត់ដំបង ដើម្បីចុះអនុវត្តសេចក្ដីជូនដំណឹង លេខ ១២៨៨ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃនាមដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្ដម នុត សារ៉ាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្ដម ធិក ត្រឿងឧត្ដា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធាន

៣- ឯកឧត្ដម ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង អនុប្រធាន

៤- ឯកឧត្ដម កុល ទីរក្ស អគ្គាធិការរងនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល សមាជិក

៥- ឯកឧត្ដម មាស សារឹម នាយករងខុទ្ទកាល័យឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

៦- លោក សួន ស៊ីផាត ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល និង ជាលេខាធិការដ្ឋានស្ថិរយោធីថ្នាក់ជាតិនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៧- លោកឧត្ដមសេនីយទោ ប៊ុន សេង មេបញ្ជាការយោធភូមិភាគទី៥ សមាជិក

៨- លោក ស្រី សុបិន អភិបាលរងខេត្តបាត់ដំបង សមាជិក

៩- លោក សៀង ស៊ុគថេង អភិបាលរងខេត្តបាត់ដំបង សមាជិក

១០- លោក ឈួន សុខា អនុប្រធាននាយកដ្ឋានកសិកម្មនៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

១១- លោក សោម សាបាន អនុប្រធាននាយកដ្ឋានទទួលបន្ទុកស្រាវជ្រាវនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង

| | | | |
|---|---|---|---|
| | | អធិការកិច្ច | សមាជិក |
| ១២- | លោក កែន សេរីរដ្ឋា | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ១៣- | លោក សុខ លីនណា | អនុប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤- | លោក សូ សុផាន់ណា | អនុប្រធាននាយកដ្ឋានអធិការកិច្ចក្រសួងមហាផ្ទៃ | សមាជិក |
| ១៥- | លោកស្រី សុខ សម្បត្តិ | ជំនួយការផ្ទាល់ឯកឧត្តម នុត សារអាន | សមាជិក |
| ១៦- | លោក ឆាយ យួប | ប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ១៧- | លោក ខួន រតនៈ | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត | សមាជិក |
| ១៨- | លោក ឌុខ គីរម្យ | ប្រធានខ័ណ្ឌរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៩- | លោក ឌុំ ស៊ីប | អភិបាលស្រុកសំពៅលូន | សមាជិក |
| ២០- | លោក ស៊ិន ញ៉ា | អភិបាលស្រុកភ្នំព្រឹក | សមាជិក |
| ២១- | លោក សុខ គង់ | អភិបាលស្រុកកំរៀង | សមាជិក |
| ២២- | លោក ព្រុំ សុផាន | អភិបាលស្រុកបវេល | សមាជិក |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- ចុះផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ដែនជំរកសត្វព្រៃនាមដូនសំអំពីស្មារតីយោគយល់និងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះប្រជាពលរដ្ឋ ។
- ចាត់ចែងចុះស្រង់ស្ថិតិប្រជាពលរដ្ឋដែលកំពុងរស់នៅ និងគ្រប់គ្រងផ្ទៃដីជាក់ស្តែងឱ្យច្បាស់លាស់ ។
- ចាត់ចែងធ្វើការបោះបង្គោលកំណត់តំបន់ស្នូល ហាមចូលរុករានយកដីបន្ថែម ។
- ធ្វើគំរោងថវិកាចំណាយសំរាប់ដំណើរការការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។
- ពេលចុះធ្វើការងារជាក់ស្តែងចប់សព្វគ្រប់ហើយ ត្រូវធ្វើសេចក្តីព្រាងព្រះរាជក្រឹត្យថ្មីដើម្បីធ្វើវិសោធនកម្មព្រះរាជក្រឹត្យចាស់ ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ ។
- ត្រូវធ្វើរបាយការណ៍គ្រប់សកម្មភាពដែលខ្លួនសំរេចបានជូនរាជរដ្ឋាភិបាលជ្រាបដើម្បីផ្តល់មតិដឹកនាំបន្ត ។

**ប្រការ៣ :** គ្រប់ការចំណាយក្នុងការបំពេញភារកិច្ចរបស់ខ្លួន គណៈកម្មការនោះត្រូវស្នើសុំថវិកាពីទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៤ :** សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និងបំពេញភារកិច្ចរៀងៗខ្លួនតាមការអញ្ជើញនិងការចាត់តាំងរបស់ប្រធាន ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងឯកឧត្តម អស់លោកដូចមានឈ្មោះក្នុងប្រការ១ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រាជធានីភ្នំពេញ. ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៤**

ជ. នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**ចម្លងជូន :**

- ទីស្តីការរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

  " ដើម្បីជូន និងថ្វាយជ្រាប "
- ដូចប្រការ១ និងប្រការ៥ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩២ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការជាតិ ដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំង និង ទប់ស្កាត់ អំពើភេរវកម្ម

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
